តើវាពិត ជា អកុសល ?

ការរំលាយ គណបក្សសង្គ្រោះជាតិ តើវាពិតជាអកុសល សំរាប់ប្រជាជាតិខ្មែរ ?

យើងឃើញថា ពីកំណើត គណបក្សនេះ បានរចិត ទ្រឹស្តី និង កម្មវិធី ដែលខ្លួនយកវាមកអួត និង ស្វែង អនុវត្ត តាម សំដី និង ដងប៉ាកកា សែនទ្វី។ តែគ្មានពោលអះអាង នៅក្នុង សង្គមជាតិ និង ប្រជាការ យ៉ាងគ្រប់គ្រាន់ នូវ សេចក្តីប្រាថ្នា តាម សកម្មភាព ដែលជា ការបង្ហាញ នៃ សមិទ្ធិកម្ម នៃ គោលគំនិតផ្ទាល់ របស់ខ្លួន។ ដូច្នេះ គណបក្សនេះ មាន មហិទ្ធានុភាពទ្រឹស្តីពិត តែគ្មានសកម្មភាព ឬ មិនបានប្រព្រឹត្ត ប្រឆាំងនឹង គូសត្រូវនយោបាយ របស់ខ្លួន, វាយប្រហារ ដោយ ប្រយោល អង្គការ ឬ ស្ថាប័ន បដិប្រជាធិបតេយ្យ, មិនបាន ជួយដាស់ នូវ ស្មារតី នៃ ការបះបោរ ដល់អ្នកគាំទ្រខ្លួន ឬ ធ្វេស ប្រហែស ដឹកនាំ ប្រឆាំងនឹង សត្រូវ ដែលប្រឆាំងខ្លួន។ កង្វះ ទាំងនេះ ដែលនាំ គណបក្សសង្គ្រោះជាតិ មិនជ្រាប ឬ មិនជ្រាតចូល ទៅក្នុង ប្រជានិការ ដោយរកមិនឃើញ នូវ វិញ្ញាប័នសាមញ្ញ[1] ដែលអាចសង្ខេប នូវ ពាក្យទោល ដែលនាំបង្កើត នូវ ប្រជាស្មារតី ក្លៀវក្លា នៅក្នុង បរិបទនយោបាយពិសេសមួយ

[1] វិញ្ញាប័នសាមញ្ញ, ការផ្ទែងសាមញ្ញ។

តើវាពិត ជា អកុសល ?

ដែលខ្លួន មាន បេសកកម្មពិសេស សំរាប់សង្គ្រោះជាតិ។ នៅ ចំពោះមុខ អំណាចផ្តាច់ការ ត្រូវគិតពិចារណាពិត តែ អំពើ អ សម្បជញ្ញៈ, អំពើ ពាយដាយ គួរប្រាថ្នា អោយកើតមាន ដ្បិត វា មិនគ្រាន់តែជា គ្ំរូ តែ វាអាចអោយស្តារតី រំដោះខ្លួនចេញពី ការខ្លាច និង ដំណើរច្រអូសក្រៃពេក ជាទំលាប់ក្រិន ដើម្បី កំរើ កការតស៊ូ។ ព្រោះ គ្ំនិតតស៊ូ កើតនៅក្នុងសកម្មភាព បន្ត១ ហើយកើតមានថ្មី មិនចេះចប់ : ត្រូវដឹងថា សេចក្តីក្លាហាន, ចិត្តតស៊ូ, ការបូជាខ្លួនចំពោះការតស៊ូ ជារោគឆ្លង ដូចគ្នានឹង ការកំសាក, ការស្តាប់បង្គាប់ និង ភាពនោទ្ធា នោះដែរ។ មាន តែ មនុស្សមុះមុត ជាអ្នកដឹងច្បាស់ថា ខ្លួនត្រូវហ៊ានប៉ុណ្ណាទៅ ដើម្បី ចាប់យកជ័យជំនះ។ គឺ ពួកអ្នកយាម អំពើយុត្តិធម៌ ដែលត្រូវគេឈ្លានពាន ស្ម័គ្រចិត្ត ចូលតស៊ូ មុន ប្រជាការ ក្រែ រក្រោធ ត្រប់ត្រាន់ ដើម្បី លើកទង់តស៊ូ នាំគ្នាដើរ ប្រឈម ប្រឆាំងនឹង សត្រូវនឹងយុត្តិធម៌។ ពួកអ្នកមានចិត្តមុះមុត ទាំងឡាយនោះឯង ជា មេដឹកនាំពិតប្រាកដ នៃ ការតស៊ូ ប្រឆាំងនឹងអំណាចផ្តាច់ការ ផ្ទុយពី ពួកអ្នកដឹកនាំ គណបក្ស សង្គ្រោះជាតិ មានប្រជាប្រិយភាពពិត តែ ជ្រើសយកផ្លូវ ចូល ធ្វើសហការ ជាមួយនឹង ពួកអ្នកផ្តាច់ការ ហើយ ល្បងរាស្ត្រ ១ ដេកចាំតែបោះឆ្នោត នៅចំពោះមុខ រាល់ព្រឹត្តិការណ៍ សង្គម និង នយោបាយ ដែលមានកើតឡើង នៅក្នុងប្រទេស។ ការណ៍ នេះ សួរថា តើ ជា ការភាន់ច្រឡំ នៃ យុទ្ធសាស្ត្រ ឬ ជា កំហុស នយោបាយ និង សីលធម៌ ?

តើវាពិត ជា អកុសល ?

តើ គណបក្សសង្គ្រោះជាតិ រលាយ ទុកជា អកុសល សំរាប់ប្រជាជាតិ ?

ត្រូវដឹងថា ពួកអ្នកដឹកនាំ គណបក្សសង្គ្រោះជាតិ មានចំណែកក្នុងអំពើខុសប្រក្រតី ហើយចូលរួមនៅក្នុងស្ថាប័ន នៃ របបផ្តាច់ការ តាំងពីយូរយារមកហើយ ម្លោះហើយ បក្សនេះ ជា វត្ថុធាតុមួយ នៃ អកុសល ដូចបក្សកាន់អំណាច នោះដែរ។ មានជាឧទាហរណ៍ : លោក សម រង្ស៊ី និង កឹម សុខា កុហករាស្ត្រ រីឯលោក ហ៊ុន សែន វិញ គាត់ សម្លុតរាស្ត្រ រួចនាំគ្នា ចែកប្រយោជន៏គ្នាមានខសន្យាខ្សីបៗ ដែលមានឈ្មោះថា វប្បធម៏សន្ទនា។ នៅពេលគាត់ឈ្លោះគ្នា រាស្ត្រមិនដឹងថា មកពីហេតុផលអ្វីផងដូច្នេះ វាជាការពិបាកមួយ ដើម្បី ធ្វើសុភវិនិច្ឆ័យ លើ ទំនាស់រវាង បក្សទាំងពីរ នៅក្នុង អវកាស នៃ អកុសល[2] ដែលម្នាក់ៗសុទ្ធតែមានចំណែក។ តែ អ្នកដែលទទួលថ្មបាក់ គឺ ប្រជាពលរដ្ឋខ្មែរ ត្រូវបន្តរស់ ក្រោមរបបផ្តាច់ការ បំរើផលប្រយោជន៏ចិន និង យួន។ ខ្មែរយើងកុំនាំគ្នាយល់ច្រឡំថា គណបក្សសង្គ្រោះជាតិ រលាយ គឺ លទ្ធិប្រជាធិបតេយ្យរលាយ ព្រោះ លទ្ធិនេះមិនដែលមានទេ នៅស្រុកខ្មែរ ក្រៅពី ការបោះឆ្នោតបញ្ឆោត រាស្ត្រ តែប៉ុណ្ណោះ។ តែបើគេបោកបានរាល់ពេល យើងគួរបារម្ភដែរ អំពី គុណសម្បត្តិ របស់រាស្ត្រខ្មែរ៕

---

[2] អវកាស នៃ អកុសល ; espace du mal។